**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង សម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥។ គណៈកម្មការនេះសរសេរជាអក្សរកាត់ថា "**គ.អ.ម.ក.**"។

**មាត្រា២ .-**

គណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ មានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| ១- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | អនុប្រធាន |
| ៣- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| ៤- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| ៥- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ១រូប | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១រូប | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| ៩- អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | សមាជិក |
| ១០- អនុរដ្ឋលេខាធិការក្រសួងផែនការ | ១រូប | សមាជិក |
| ១១- អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១រូប | សមាជិក |
| ១២- អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | សមាជិក |
| ១៣- អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១រូប | សមាជិក |
| ១៤- អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | ១រូប | សមាជិក |
| ១៥- តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១រូប | សមាជិក |
| ១៦- តំណាងក្រុមប្រឹក្សាអ្នកច្បាប់ | ១រូប | សមាជិក |
| ១៧- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | ១រូប | សមាជិក |
| ១៨- តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១រូប | សមាជិក |
| ១៩- អគ្គលេខាធិការរងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | ១រូប | សមាជិក |
| ២០- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១រូប | សមាជិក |
| ២១- អគ្គនាយកនៃធនាគារជាតិនៃកម្ពុជា | ១រូប | សមាជិក |
| ២២- អគ្គនាយកនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១រូប | សមាជិក |

២៣- អគ្គនាយកនៃក្រសួងអភិវឌ្ឍន៍ជនបទ ១រូប សមាជិក

២៤- អគ្គនាយកនៃក្រសួងរ៉ែនិងថាមពល ១រូប សមាជិក

២៥- ប្រធានទីភ្នាក់ងារជាតិមុខរបរនិងការងារ សមាជិក

២៦- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក។

**គ.អ.ម.ក.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ សមាគមនិយោជក សហជីព អង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានាចូលរួមផ្តល់យោបល់តាមការចាំបាច់។

## ជំពូកទី២
## ភារកិច្ចរបស់ គ.អ.ម.ក.

**មាត្រា៣ .-**

**គ.អ.ម.ក.** មានភារកិច្ចដូចតទៅ៖

- ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥
- រៀបចំផែនការអនុវត្តវិធានការនីមួយៗនៃគោលនយោបាយ ដោយមានកំណត់ពេលវេលាជាក់លាក់
- លើកសំណើនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ដើម្បីធ្វើការសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខដែលបានកើតឡើងនៅក្នុងពេលអនុវត្ត
- រៀបចំផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាព
- សហការជាមួយអង្គការអន្តរជាតិខាងការងារនិងដៃគូអភិវឌ្ឍនានា ដើម្បីកៀរគរជំនួយបច្ចេកទេសនិងថវិកាសម្រាប់ការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឱ្យកាន់តែមានប្រសិទ្ធភាព
- កែសម្រួលនិងធ្វើបច្ចុប្បន្នកម្មគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ តាមពេលវេលានិងការចាំបាច់
- សម្របសម្រួលដំណើរការពិគ្រោះយោបល់នានា ទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិទាក់ទងនឹងការអនុវត្តគោលនយោបាយជាតិស្តីមុខរបរនិងការងារ
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាលស្តីពីវឌ្ឍនភាពនិងបញ្ហាប្រឈមនៅក្នុងការអនុវត្ត ដោយផ្អែកលើគោលដៅនិងសូចនាករដែលបានកំណត់ក្នុងគោលនយោបាយ។

## ជំពូកទី៣
## ដំណើរការរបស់ គ.អ.ម.ក.

**មាត្រា៤ .-**

អនុប្រធាននិងសមាជិក **គ.អ.ម.ក.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.អ.ម.ក.**។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានអាចកោះអញ្ជើញនិងដឹកនាំការប្រជុំជំនួសតាមការប្រគល់សិទ្ធិពីប្រធាន។

ក្នុងករណីអវត្តមានឬមានធុរៈមិនអាចចូលរួមប្រជុំបាន អនុប្រធានឬសមាជិក **គ.អ.ម.ក.** ត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេចចូលរួមប្រជុំជំនួស។/ស

**មាត្រា៥ ._**

**គ.អ.ម.ភ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ដំណើរការការងារ។

**មាត្រា៦ ._**

**គ.អ.ម.ភ.** មានអនុគណៈកម្មការអន្តរក្រសួងចំនួន៣និងគណៈកម្មការរាជធានី ខេត្តៈ

១- អនុគណៈកម្មការបង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់។

២- អនុគណៈកម្មការលើកកម្ពស់ការអភិវឌ្ឍជំនាញនិងធនធានមនុស្ស។

៣- អនុគណៈកម្មការពង្រឹងអភិបាលកិច្ចទីផ្សារការងារ។

៤- គណៈកម្មការរាជធានី ខេត្ត។

អនុគណៈកម្មការទាំង៣ ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.អ.ម.ភ.** ដែលមានសមាសភាពក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធជាសមាជិកតាមការចាំបាច់។

អនុគណៈកម្មការនីមួយៗនិងគណៈកម្មការរាជធានី ខេត្ត អាចអញ្ជើញតំណាងនិយោជក សហជីព អង្គការជាតិ និងអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា ចូលរួមផ្តល់យោបល់តាមការចាំបាច់។

**មាត្រា៧ ._**

**គ.អ.ម.ភ.** មានលេខាធិការដ្ឋានមួយសម្រាប់សម្របសម្រួលដំណើរការអនុវត្ត ដោយមានអគ្គនាយកនៃអគ្គនាយកដ្ឋានការងារជាប្រធានលេខាធិការដ្ឋាន។ លេខាធិការដ្ឋាននៃ **គ.អ.ម.ភ.** ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.អ.ម.ភ.**។

**មាត្រា៨ ._**

គណៈកម្មការរាជធានី ខេត្ត ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលមានតំណាងមន្ទីរនិងអង្គភាពពាក់ព័ន្ធជាសមាជិកតាមការចាំបាច់។ គណៈកម្មការរាជធានី ខេត្ត ត្រូវបានកំណត់ឱ្យប្រើប្រាស់ត្រារបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ដំណើរការការងារ។

គណៈកម្មការរាជធានី ខេត្ត មានលេខាធិការដ្ឋានមួយសម្រាប់សម្របសម្រួលដំណើរការ ដោយមានប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ជាប្រធាន។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៩ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ